# មគ្គុទ្ទេសក៍អំពីប្រភពធនធានសម្រាប់ជនអន្តោប្រវេសន៍

## កម្មវិធី និងសេវា ដែលផ្តល់ជូនដោយ

**Alameda County**
**Social Services Agency**

## និងដៃគូសហគមន៍

**ទីតាំងការិយាល័យ ACSSA**

**ម៉ោងធ្វើការ**
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ
8:30 am - 5:00 pm

**Thomas L. Berkley Square (North Oakland)**
2000 San Pablo Ave.
Oakland, CA 94612

**Eastmont Town Center Self-Sufficiency Center**
6955 Foothill Blvd., Suite 100
Oakland, CA 94605

**Enterprise Self-Sufficiency Center**
8477 Enterprise Way
Oakland, CA 94621

**Gail Steele Multi-Service Center**
24100 Amador St.
Hayward, CA 94544

**Fremont Office**
39155 Liberty St., Suite C330 Fremont, CA 94536

**Livermore Self-Sufficiency Center**
2499 Constitution Drive
Livermore, CA 94551

**វេបសាយ៖**
www.alamedacountysocialservices.org

**មជ្ឈមណ្ឌលបម្រើទូរស័ព្ទអតិថិជន៖**
(510) 263-2420 ឬ (888) 999-4772

**211 Alameda County**
ទូរស័ព្ទទៅលេខ 2-1-1 សម្រាប់ព័ត៌មានសម្ងាត់ និងឥតគិតថ្លៃ និងការបញ្ជូនទៅសេវាកម្មលំនៅឋាន ថែទាំសុខភាព និងសង្គមកិច្ច។
មានជូន 24 ម៉ោងរាល់ថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

**មាតិកា៖**


| | |
|---|---|
| ជំនួយម្ហូបអាហារ | 2 |
| ជំនួយវេជ្ជសាស្ត្រ | 2 |
| ជំនួយសាច់ប្រាក់ | 2 |
| ជំនួយថ្លៃឈ្នួលគ្រាអាសន្ន | 4 |
| សេវាកម្មការងារ | 6 |
| សេវាកម្មជនភៀសខ្លួន និងជនអន្តោប្រវេសន៍ | 7 |
| សេវាកម្មមនុស្សពេញវ័យ និងចាស់ជរា | 8 |
| សេវាកម្មកុមារ និងគ្រួសារ | 9 |
| ការរៀបចំបង់ពន្ធឥតគិតថ្លៃ | 11 |
| ដៃគូសហគមន៍ | 11 |


## ចំណុចសំខាន់!

- វិធានស្តីពីអត្ថប្រយោជន៍សាធារណៈ: ពុំទាន់កែប្រែឡើយ។
- ព័ត៌មាន ដែលបានផ្តល់ឲ្យ Alameda County Social Services Agency (ACSSA) គឺជាព័ត៌មានសម្ងាត់ និងត្រូវបានប្រើ ដើម្បីកំណត់លក្ខណសម្បត្តិទទួលបានអត្ថប្រយោជន៍តែប៉ុណ្ណោះ។
- បុគ្គល និងគ្រួសារអាចបន្តដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ និងសេវាកម្មទៅតាមសេចក្តីត្រូវការ។
- កុំបង់ប្រាក់ឲ្យបុគ្គលណាម្នាក់ ដើម្បីឲ្យគេជួយអ្នកក្នុងការបំពេញពាក្យស្នើសុំសម្រាប់កម្មវិធី និងសេវាកម្មរបស់ ACSSA ។ យើងនៅទីនេះ ជួយអ្នកដាក់ពាក្យស្នើសុំ!

## ជំនួយម្ហូបអាហារ

### CalFresh (ពីមុនហៅថា Food Stamps) - ជំនួយអាហារូបត្ថម្ភ

CalFresh ផ្តល់ជំនួយអាហារូបត្ថម្ភប្រចាំខែទៅឲ្យបុគ្គល និងគ្រួសារចំណូលទាប ដើម្បីទិញម្ហូបអាហារសុខភាព។ ទទួលបានអត្ថប្រយោជន៍ CalFresh តាមរយៈការប្រើប្រាស់ប័ណ្ណ EBT (ប័ណ្ណផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិក)។

លក្ខណសម្បត្តិ៖ ពលរដ្ឋអាមេរិក និងអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់** នៅទីតាំងការិយាល័យ ACSSA
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **អនឡាញ៖** https://benefitscal.com/

**Electronic Benefits Transfer (EBT) Helpline**
(បើជួយបញ្ហាផ្សេងៗទាក់ទងនឹងប័ណ្ណរបស់អ្នក)៖
1-877-328-9677

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Health-and-Food/CalFresh/index

### កម្មវិធីជំនួយម្ហូបអាហាររដ្ឋ California (CFAP) - ជំនួយអាហារូបត្ថម្ភ

ជំនួយពីមូលនិធិរដ្ឋ ដើម្បីទិញម្ហូបអាហារូបត្ថម្ភ សម្រាប់បុគ្គលមានលក្ខណសម្បត្តិដែលមិនមែនជាពលរដ្ឋ ដែលគ្មានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់រដ្ឋសហព័ន្ធ។

លក្ខណសម្បត្តិ៖ ជនអន្តោប្រវេសន៍ភាគច្រើន – អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់

ពាក្យស្នើសុំ CFAP គឺដូចគ្នានឹងដំណើរការនៃពាក្យស្នើសុំ ដែលបានប្រើសម្រាប់កម្មវិធី CalFresh។

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ ACSSA
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **អនឡាញ៖** https://benefitscal.com/

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Health-and-Food/CalFresh/index#eligibility

## ជំនួយវេជ្ជសាស្ត្រ

### Medi-Cal – ការទទួលបានសេវាថែទាំសុខភាព

ការធានារ៉ាប់រងសុខភាពឥតគិតថ្លៃ ឬចំណាយតិចសម្រាប់កុមារ គ្រួសារ ចាស់ជរា និងបុគ្គលមានពិការភាព ដែលចំណូល និងធនធានមានកម្រិត។

លក្ខណសម្បត្តិ៖ ពលរដ្ឋ California ដោយមិនគិតពីឋានៈអន្តោប្រវេសន៍ឡើយ។ (មានប្រសិទ្ធភាពពីខែមករា ឆ្នាំ 2026 តទៅ បុគ្គលមិនមែនជាពលរដ្ឋអាមេរិក ឬអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ នឹងមានលក្ខណសម្បត្តិចុះឈ្មោះតែក្នុងកម្មវិធី restricted ឬ limited scope Medi-Cal ប៉ុណ្ណោះ។

**របៀបស្នើសុំ៖**

- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ ACSSA
- **តាមប្រៃសណីយ៍៖** ទូរស័ព្ទទៅ 510-263-2420 ឬ1-888-999-4772 (ឥតគិតថ្លៃទូរស័ព្ទ) ដើម្បីស្នើសុំពាក្យសុំ Medi-Cal ដែលផ្ញើតាមប្រៃសណីយ៍ និងកូនសៀវភៅណែនាំ
- **តាមទូរសារ៖** អ្នកអាចផ្ញើពាក្យសុំ Medi-Cal ដែលបានបំពេញរួចរបស់អ្នក ទៅ (510) 670-5095
- **អនឡាញ៖** https://benefitscal.com/ ឬតាម Covered California នៅ CoveredCa.com

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Health-and-Food/Medi-Cal/index

## ជំនួយសាច់ប្រាក់

### Refugee Cash Assistance (RCA)

ផ្តល់ជំនួយសាច់ប្រាក់រហូតដល់ចំនួន 4 ខែ ទៅឲ្យបុគ្គលដែលមានលក្ខណសម្បត្តិ នៅក្រោយថ្ងៃទី 5 ខែឧសភា ឆ្នាំ2025។ សម្គាល់៖ បុគ្គល ដែលមានលក្ខណសម្បត្តិ នៅមុនថ្ងៃទី 5 ខែឧសភា ឆ្នាំ 2025 អាចទទួលបានជំនួយសាច់ប្រាក់រហូតដល់ចំនួន 12 ខែ។

អ្នកទទួលជំនួយ RCA ក៏ត្រូវចុះឈ្មោះក្នុងកម្មវិធីការងារ និងបណ្តុះបណ្តាល ដើម្បីជួយពួកគេរកការងារធ្វើ និងទទួលបានសេវាកម្មគាំពារជនភៀសខ្លួនបន្ថែមទៀត។ អ្នកចូលរួមត្រូវបានតម្រូវឲ្យចូលរួមក្នុងសេវាកម្មការពារ ដែលជាលក្ខខណ្ឌនៃលក្ខណសម្បត្តិទទួលបាន RCA។

លក្ខណសម្បត្តិ៖ ជនភៀសខ្លួន អ្នកសុំសិទ្ធិជ្រកកោន កូនកាត់អាមេរិកពីវៀតណាម ជនរងគ្រោះនៃអំពើជួញដូរមនុស្សដែលបានទទួលស្គាល់ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងបទល្មើសធ្ងន់ធ្ងរផ្សេងទៀត និងអ្នកកាន់ទិដ្ឋាការអន្តោប្រវេសន៍អ៊ីរ៉ាក់ និងអាហ្វហ្គានីស្ថានពិសេស អាចមានលក្ខណសម្បត្តិទទួលបាន RCA។

**របៀបស្នើសុំ៖**
- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ ACSSA
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **តាមអនឡាញ៖** https://benefitscal.com/
- **តាមប្រៃសណីយ៍៖** អ្នកអាចផ្ញើពាក្យសុំរបស់អ្នកតាមប្រៃសណីយ៍ទៅប្រអប់សំបុត្រ P.O. Box 12941, Oakland, CA 94604

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Immigrants-and-Refugees/RCA.

## Cash Assistance Program for Immigrants (CAPI)

CAPI ផ្តល់ជំនួយជូនបុគ្គលស្របច្បាប់ មិនមែនជាពលរដ្ឋ ដែលខ្វះខាតហិរញ្ញវត្ថុ និងគ្មានលក្ខណសម្បត្តិទទួលបានចំណូលសន្តិសុខបន្ថែម (Supplemental Security Income (SSI)) របស់រដ្ឋសហព័ន្ធ ដោយសារឋានៈអន្តោប្រវេសន៍។ លក្ខណសម្បត្តិ ផ្អែកលើស្ថានការណ៍នីមួយៗ។

លក្ខណសម្បត្តិ៖ ជនអន្តោប្រវេសន៍ពិការ ឬពិការភ្នែកគ្រប់វ័យ ឬចាស់ជរាអាយុ 65 ឆ្នាំ និងលើសនេះ ដែល

- គ្មានលក្ខណៈសម្បត្តិទទួលបានចំណូលសន្តិសុខបន្ថែម/ប្រាក់បន្ថែមពីរដ្ឋ (Supplemental Security Income/State Supplementary Payment (SSI/SSP)) ដោយសារតែឋានៈអន្តោប្រវេសន៍ និង
- គ្មានចំណូល ឬចំណូលមានកម្រិត ទ្រព្យសរុបតិចជាង $2,000 បើនៅលីវ និងមិនលើសពី $3,000 បើរៀបការរួច។

**របៀបស្នើសុំ៖**
- **ដោយផ្ទាល់៖** នៅទីតាំងការិយាល័យ ACSSA
- **ទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **ប្រៃសណីយ៍៖** P.O. Box 12941 Oakland, CA 94604
- **ទូរសារ៖** 510-670-5095

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Immigrants-and-Refugees/CAPI

## CalWORKs (California Work Opportunities and Responsibilities to Kids)

ផ្តល់ជំនួយសាច់ប្រាក់សម្រាប់រយៈពេលមានកំណត់ សេវាកម្មការងារ សេវាកម្មគាំពារ និង/ឬសេវាកម្មអ្នកគ្មានផ្ទះសម្បែង ដោយផ្អែកលើចំណូលបុគ្គល និងចំណូលគ្រួសារ ទៅឲ្យគ្រួសារមានលក្ខណសម្បត្តិ ដែលមានកូននៅផ្ទះ។

បើគ្មានការលើកលែងទេ អ្នកទទួលជំនួយ CalWORKs ត្រូវបានតម្រូវឲ្យចូលរួមក្នុងសកម្មភាព Welfare- to-Work (WtW) ឬធ្វើការចំនួន 20 ម៉ោងក្នុងមួយសប្តាហ៍ ចំពោះគ្រួសារពោះម៉ាយ/មេម៉ាយមានកូនម្នាក់អាយុក្រោម 6 ឆ្នាំ ធ្វើការចំនួន 30 ម៉ោងក្នុងមួយសប្តាហ៍ចំពោះគ្រួសារពោះម៉ាយ/មេម៉ាយ គ្មានកូនអាយុក្រោម 6 ឆ្នាំ និងធ្វើការចំនួន 35 ម៉ោងក្នុងមួយសប្តាហ៍ ចំពោះគ្រួសារមានទាំងឪពុកនិងម្តាយ។

លក្ខណសម្បត្តិ៖ ពលរដ្ឋ California ដែលជា
- ពលរដ្ឋសហរដ្ឋអាមេរិក
- មិនមែនជាពលរដ្ឋ តែជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់
- បុគ្គលមានលក្ខណសម្បត្តិ មិនមែនជាពលរដ្ឋ ឬ
- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងបទល្មើសធ្ងន់ធ្ងរផ្សេងទៀត។

**របៀបស្នើសុំ៖**
- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ ACSSA
- **ទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **ប្រៃសណីយ៍៖** P.O. Box 12941 Oakland, CA 94604
- **ទូរសារ៖** 510-670-5095
- **អនឡាញ៖** https://benefitscal.com/

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Work-and-Money/CalWORKs/index

## CalWORKs Starting Out Strong Program

កម្មវិធី CalWORKs Starting Out Strong Program (SOSP) ផ្តល់ជំនួយចិញ្ចឹមថែទាំកូន ការតស៊ូមតិ និងសកម្មភាពគាំទ្រលទ្ធភាពទទួលបានការថែទាំមុន និងក្រោយពេលសម្រាលកូន ការអប់រំសុខភាព និងការចិញ្ចឹមថែទាំកូនផ្សេងៗ ដោយគិលានុបដ្ឋាក ឬអ្នកវិជ្ជាជីវៈដែលបានឆ្លងកាត់ការបណ្តុះបណ្តាល។

លក្ខណសម្បត្តិ៖
- ជាសមាជិកនៃអង្គភាពជំនួយនៃកម្មវិធី CalWORKs ឬជាឪពុក/ម្តាយ/សាច់ញាតិថែទាំក្នុងសំណុំរឿងកូនតែម្នាក់ រាប់ទាំងបុគ្គលដែលរងទណ្ឌកម្ម ឬអស់ពេលជាកំណត់។ និង
- បច្ចុប្បន្នមានផ្ទៃពោះ ឬជាឪពុក/ម្តាយ/សាច់ញាតិថែទាំកុមារអាយុតិចជាង 36 ខែ។

**របៀបស្នើសុំ៖**
- **ដោយផ្ទាល់៖** នៅទីតាំងការិយាល័យ ACSSA
- **ទូរស័ព្ទ៖** 510-667-3072
- អ៊ីម៉ែល៖ homevisiting@acgov.org

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Work-and-Money/Other-Support/CalWORKs-starting-out-strong

## General Assistance

កម្មវិធីប្រាក់កម្ចីឧបត្ថម្ភដោយខោនធី ផ្តល់ជំនួយសាច់ប្រាក់ទៅឲ្យមនុស្សពេញវ័យដែលនៅលីវ ប្តីប្រពន្ធរៀបការរួច ដែលគ្មានកូនក្នុងបន្ទុក និងអនីតិជនដែលរួចពីអាណាព្យាបាលភាព។

អ្នកស្នើសុំ និងអ្នកទទួលបាន GA ក៏អាចមានលក្ខណសម្បត្តិទទួលបានជំនួយការងារ ម្ហូបអាហារ និងវេជ្ជសាស្ត្របន្ថែមផងដែរ។

លក្ខណសម្បត្តិ៖
- ពលរដ្ឋសហរដ្ឋអាមេរិក
- អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់
- បុគ្គលមិនមែនជាពលរដ្ឋ ដែលមានអ្នកឧបត្ថម្ភ ឬ
- បុគ្គលមិនមែនជាពលរដ្ឋផ្សេងទៀត ដែលអាចមានលក្ខណសម្បត្តិ៖ ការស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ ឬស្នាក់នៅអចិន្ត្រៃយ៍នៅសហរដ្ឋអាមេរិក ក្រោមគោលការណ៍ color of law PRUCOL)។

**របៀបស្នើសុំ៖**
- **ដោយផ្ទាល់៖** នៅទីតាំងការិយាល័យ ACSSA
- **អនឡាញ៖** https://gaapp.alamedacountyca.gov/#/form
- **តាមទូរស័ព្ទ៖** 1-888-999-4772 ឬ 510-263-2420
- **ប្រៃសណីយ៍៖** P.O. Box 12941 Oakland, CA 94604
- **ទូរសារ៖** 510-670-5095

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Work-and-Money/General-Assistance/index

# ជំនួយថ្លៃជួលក្នុងគ្រាអាសន្ន

## Season of Sharing

Season of Sharing ផ្តល់ជាជំនួយមួយលើក ផ្អែកលើវិបត្តិចំពោះសេចក្តីត្រូវការសំខាន់ និងសេចក្តីត្រូវការលំនៅឋានអចិន្ត្រៃយ៍ទៅឲ្យពលរដ្ឋនៃខោនធី Alameda។ កម្មវិធីនេះចង់ជួយគ្រួសារមានលក្ខណៈសម្បត្តិ ឲ្យទទួលបានស្ថេរភាពឡើងវិញ បន្ទាប់ពីជួបស្ថានការណ៍គ្រាអាសន្ន ដែលមិនអាចប្រមើលឃើញ ដែលហួសពីការគ្រប់គ្រងរបស់ពួកគេ។

លក្ខណៈសម្បត្តិ៖
- អ្នកស្នើសុំត្រូវតែជាពលរដ្ឋនៃខោនធី Alameda ដែលរស់នៅក្នុងខោនធីរយៈពេល 6 ខែ ឬរយៈពេលវែងជាងនេះ។
- មនុស្សពេញវ័យទាំងអស់ក្នុងគ្រួសារមិនបានទទួលជំនួយពី SoS Fund ក្នុងរយៈពេល 5 កន្លងមកនេះ។
- គ្រួសារប្រឈមនឹងហានិភ័យនៃភាពគ្មានផ្ទះសម្បែង ឬក៏អស្ថេរភាពនៃលំនៅឋាន ឬក៏បច្ចុប្បន្ន គ្មានផ្ទះសម្បែង។
- អ្នកស្នើសុំចម្បង មានអាយុ 18 ឆ្នាំ ឬលើសនេះ។
- គ្រួសារកំពុងជួប ឬបានជួបស្ថានភាពគ្រាអាសន្ន វិបត្តិ ឬក៏ហេតុការណ៍មិនរំពឹងទុក ក្នុងរយៈពេល 6 ខែកន្លងមកនេះ ដែលចាំបាច់ត្រូវការជំនួយហិរញ្ញវត្ថុ ដើម្បីរក្សា ឬលើកកម្ពស់ស្ថេរភាពគ្រួសារ។

ការស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់មិនមែនជាលក្ខខណ្ឌតម្រូវឡើយ។

ឯកសារនឹងត្រូវការ ដើម្បីបញ្ជាក់លក្ខណសម្បត្តិរបស់គ្រួសារនីមួយៗនិងស្ថានភាពគ្រាអាសន្ន។ ការបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃលក្ខណសម្បត្តិ ឬការបំពេញនូវដំណើរការស្នើសុំមិនមែនជាការសន្យា ឬធានាផ្តល់ជំនួយឡើយ។ ដោយសារធនធានមានកម្រិត ជំនួយត្រូវបានសម្រេចផ្តល់ជូន ដោយផ្អែកលើបញ្ហាវិបត្តិ និងការលំបាកហិរញ្ញវត្ថុ ដែលមានឯកសារបញ្ជាក់។ កម្មវិធី SoS មិនអាចរ៉ាប់រងរាល់ចំណាយទាំងអស់ ដែលគ្រួសារជំពាក់ឡើយ។

**របៀបស្នើសុំ៖**
ដើម្បីចាប់ផ្តើមសំណើ SoS សូមបំពេញទម្រង់ Client Web Form លើប្រព័ន្ធអនឡាញ នៅ៖
https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/Other-Support/season-of-sharing

## CalWORKs Housing Support Program

កម្មវិធី CalWORKs Housing Support Program ផ្តល់ជំនួយទៅឲ្យគ្រួសារ CalWORKs ដែលបានទទួលអត្ថប្រយោជន៍ CalWORKs និងត្រូវការជំនួយដើម្បីទទួលបាន ឬរក្សាលំនៅឋានអចិន្ត្រៃយ៍។

សេវាកម្មគាំពារមួយចំនួន ដែលផ្តល់ជូន រួមមាន ជំនួយថ្លៃជួល ការជ្រើសរើសលំនៅឋាន ការគ្រប់គ្រងសំណុំរឿង ប្រាក់កក់តម្កល់ធានា ការបង់ថ្លៃទឹកភ្លើង ថ្លៃផ្លាស់ទីលំនៅ ជំនួយទីជម្រកបណ្តោះអាសន្ន សេវាកម្មផ្លូវច្បាប់ និងការស្តារពិន្ទុក្រេឌីតឡើងវិញ។

លក្ខណសម្បត្តិ៖
- មានសំណុំរឿង CalWORKs បច្ចុប្បន្ន និង
- មិនមានទីលំនៅជាប់លាប់ ឬ
- មានសេចក្តីជូនដំណឹងបណ្តេញចេញ ដែលបង្គាប់ដោយតុលាការ។

**របៀបស្នើសុំ៖**
គ្រួសារត្រូវបានបុគ្គលិកសង្គមកិច្ចនៃទីភ្នាក់ងារសេវាកម្មសង្គមកិច្ចខោនធី Alameda បញ្ជូនមកកាន់កម្មវិធីនេះ។ ធ្វើដំណើរទៅការិយាល័យនៅជិតបំផុត ដើម្បីជជែកជាមួយបុគ្គលិកសង្គមកិច្ច ឬស្នើសុំការបញ្ជូនពីបុគ្គលិកផ្នែកលក្ខណសម្បត្តិ ឬទីប្រឹក្សាការងារ ដើម្បីជជែកជាមួយបុគ្គលិកសង្គមកិច្ច។

**សម្រាប់ព័ត៌មានបន្ថែម៖**
**វេបសាយ៖**
[https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/CalWORKs-housing-assistance/index#housingsupport](https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/CalWORKs-housing-assistance/index#housingsupport)

## Housing Assistance for Ukrainians (HAU)

កម្មវិធី HAU គឺជាសេវាកម្មគាំពារ ដែលផ្តល់ជំនួយលំនៅឋាន និងថ្លៃទឹកភ្លើងដោយផ្ទាល់ និងផ្តល់សេវាកម្មគាំពារផ្សេងទៀត ទៅឲ្យគ្រួសារមានលក្ខណសម្បត្តិ ដែលក្នុងនោះ រួមមាន៖

- ជំនួយថ្លៃជួល
- ជំនួយប្រាក់កក់តម្កល់
- ជំនួយថ្លៃទឹកភ្លើង
- ការគ្រប់គ្រងសំណុំរឿងកម្រិតទាប

<u>លក្ខណសម្បត្តិ៖</u>
ជនជាតិអ៊ុយក្រែនបានសិទ្ធិចូលទឹកដីអាមេរិកបណ្តោះអាសន្នក្រោមលក្ខខណ្ឌមនុស្សធម៌ (Ukrainian humanitarian parolees (UHP)) និងអ្នកបានសិទ្ធិចូលទឹកដីអាមេរិកបណ្តោះអាសន្នផ្សេងទៀត នៅក្រោមកម្មវិធី Uniting for Ukraine ពីថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2022 ដល់ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2024។ អ្នកមានលក្ខណសម្បត្តិ រួមបញ្ចូលជនជាតិអ៊ុយក្រែន និងអ្នកផ្សេងទៀតមិនមែនជាជនជាតិអ៊ុយក្រែន ដែលត្រូវបានបង្ខំឲ្យផ្លាស់ទីជម្រកចេញពីប្រទេសអ៊ុយក្រែន។

ពាក្យស្នើសុំនឹងទទួលយក រហូតដល់ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2025។

**របៀបស្នើសុំ៖**
សូមទាក់ទងអ្នកផ្តល់សេវាកម្មខាងក្រោមតាមទូរស័ព្ទ ឬអ៊ីម៉ែល៖

- ប្រសិនបើអ្នករស់នៅក្នុងទីក្រុង Albany, Berkeley, Emeryville, Oakland, Alameda, Piedmont, San Leandro, និង San Lorenzo នៅភាគខាងជើងរបស់ខោនធី សូមទាក់ទង៖

  Lao Family Community Development
  ទូរស័ព្ទ៖ (510) 694-0086 ឬ (510) 533-8850
  អ៊ីម៉ែល៖ [zthein@lfcd.org](mailto:zthein@lfcd.org)

- ប្រសិនបើអ្នករស់នៅក្នុងទីក្រុង Hayward, Castro Valley, Ashland, Cherryland, Fairview, Dublin, Pleasanton, Livermore, Fremont, Union City, និង Newark នៅភាគខាងត្បូងរបស់ខោនធី សូមទាក់ទង៖

  The Alliance for Community Wellness (La Familia)
  ទូរស័ព្ទ៖ (510) 935-9293
  អ៊ីម៉ែល៖ [mamini@livelafamilia.org](mailto:mamini@livelafamilia.org)

## Refugee Housing Support Program (RHSP)

ផ្តល់ជំនួយលំនៅឋានរហូតដល់ 12 ខែ ក្នុងរយៈពេល 12 ខែដំបូង ដែលមានលក្ខណសម្បត្តិ ផ្អែកតាម Office of Refugee Resettlement (ORR)។ កម្មវិធី RHSP ផ្តល់ជំនួយដូចខាងក្រោម៖

- ជំនួយថ្លៃជួលរហូតដល់ 12 ខែ។
- ជំនួយប្រាក់កក់តម្កល់។
- ជំនួយថ្លៃប្រើប្រាស់រហូតដល់ 12 ខែ ដោយរ៉ាប់រងថ្លៃចំណាយប្រចាំខែ។

<u>លក្ខណសម្បត្តិ៖</u>

- បុគ្គលិក ដែលលក្ខណសម្បត្តិ ORR ចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី 1 ខែតុលា ឆ្នាំ 2024 និង
- រស់នៅក្នុងខោនធី Alameda ។ និង
- ស្ថិតនៅក្នុងប្រភេទលក្ខណសម្បត្តិ ORR ខាងក្រោមណាមួយ៖
  - <u>ជនភៀសខ្លួន</u> ដែលទទួលបានឋានៈជនភៀសខ្លួនក្នុងអំឡុងពេល 12 ខែដំបូង ដែលមានលក្ខណសម្បត្តិ ORR។
  - <u>អ្នកកាន់ទិដ្ឋាការអន្តោប្រវេសន៍ពិសេស (Special Immigrant Visa (SIV))</u> ពីអ៊ីរ៉ាក់។
  - <u>ជនសុំសិទ្ធិជ្រកកោន</u> ដែលទទួលបានសិទ្ធិជ្រកកោននៅ ឬក្រោយថ្ងៃទី 1 ខែតុលា ឆ្នាំ 2024។
  - <u>ជនជាតិគុយបា/ហៃទី</u> ដែលទទួលបានសិទ្ធិចូលទឹកដីអាមេរិក។
  - ជនជាតិអាស៊ីកាត់អាមេរិក
  - <u>ជនរងគ្រោះនៃអំពើជួញដូរ</u> ដែលទទួលបានឋានៈពីក្រសួងសុខាភិបាល និងសង្គមកិច្ចសហរដ្ឋអាមេរិក។

**របៀបស្នើសុំ៖**
**តាមទូរស័ព្ទ៖**

- (510) 452-8222 (International Rescue Committee (IRC) Oakland)
- (925) 927-2000 (Jewish Family & Community Services – East Bay (JFCS-EB)
- (408) 358-3636 (Jewish Family Services – Silicon Valley (JFS-SV)

# សេវាកម្មការងារ

## កម្មវិធី Welfare-to-Work (WTW)

កម្មវិធី Welfare-to-Work ជាផ្នែកស្វែងរកការងារ និងបណ្ដុះបណ្ដាល នៃកម្មវិធី CalWORKs ដែលផ្ដល់ជូនអ្នកចូលរួមនូវឧបករណ៍ ដើម្បីអាចពឹងពាក់ខ្លួនឯងបាន តាមរយៈការងារ។ សេវាកម្ម ដែល ACSSA ផ្ដល់ទៅឲ្យអ្នកទទួល CalWORKs បច្ចុប្បន្ន រួមបញ្ចូលការបណ្ដុះបណ្ដាល និងរកការងារឲ្យធ្វើ ការសម្របខ្លួនក្នុងសង្គម ការគ្រប់គ្រងសំណុំរឿង ការអប់រំមូលដ្ឋានសម្រាប់មនុស្សពេញវ័យ (Adult Basic Education)/ GED ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការអប់រំ ការបង្រៀនអង់គ្លេសជាភាសាវិជ្ជាជីវៈទីពីរ និងសេវាកម្មគាំពារផ្សេងៗ ដូចជា ការថែទាំកុមារ ការដឹកជញ្ជូន និងថ្លៃចំណាយនៃការអប់រំ និងបណ្ដុះបណ្ដាល។

<u>លក្ខណសម្បត្តិ៖</u>

បុគ្គល ត្រូវតែស្នើសុំ ឬក៏ទទួល CalWORKs នាបច្ចុប្បន្ន ដើម្បីចូលរួមក្នុងកម្មវិធី WTW។

**របៀបស្នើសុំ៖**

- ដើម្បីស្នើសុំ CalWORKs **ធ្វើដំណើរទៅការិយាល័យ ACSSA** ឬ **តាមអនឡាញនៅ** http://benefitscal.com
- អ្នកទទួល CalWORKs បច្ចុប្បន្ន អាចទាក់ទង**ទីប្រឹក្សាការងារ**ជាកំណត់របស់ខ្លួន ដើម្បីសាកសួរអំពីកម្មវិធី WTW។

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖**

https://www.alamedacountysocialservices.org/our-services/Work-and-Money/Employment-and-Training/Welfare-to-work

## កម្មវិធី CalFresh Employment & Training (CF E&T) Program

សេវាកម្ម ដែលផ្ដល់ជូនអ្នកចូលរួម ដែលមានលក្ខណសម្បត្តិ ដើម្បីជួយពួកគេស្វែងរកការងារ រួមមាន៖

- តេស្តវាយតម្លៃ
- សិក្ខាសាលា Job Club អំពីការរៀបចំប្រវត្តិរូប (resume) និងពាក្យសុំការងារ។ ជំនាញសម្ភាសន៍ ដំបូន្មានស្វែងរកការងារ និងការរក្សាការងារ។
- ជំនួយស្វែងរកការងារ និងព័ត៌មាន
- ការអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការសិក្សាត្រៀម GED

អ្នកចូលរួមក៏អាចទទួលសេវាកម្មគាំពារ និងជំនួយលើការធ្វើដំណើរ ថ្លៃចំណាយការងារ ឬបណ្ដុះបណ្ដាល ថ្លៃសិក្សា ថ្លៃតេស្តប្រឡង សៀវភៅ និងសម្ភារសិក្សាផ្សេងៗ។

<u>លក្ខណសម្បត្តិ៖</u>

- អាចធ្វើការងារបាន
- កំពុងទទួល CalFresh ឬ Transitional CalFresh និងមិនកំពុងទទួល CalWORKs ទេ។

នេះគឺជាកម្មវិធីស្ម័គ្រចិត្ត។

**របៀបស្នើសុំ៖**

- **អ្នកទទួល CalFresh បច្ចុប្បន្នអាចសាកសួរនៅការិយាល័យ ACSSA ឬជាមួយអ្នកបច្ចេកទេសផ្នែកសេវាកម្មលក្ខណសម្បត្តិ ឬទូរស័ព្ទទៅលេខ 510-263-2420**។
- ដើម្បីស្នើសុំ CalFresh សូមមើលទំព័រទី 2។
- ដើម្បីស្នើសុំកម្មវិធី General Assistance សូមមើលទំព័រទី 4។

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖**

https://www.alamedacountysocialservices.org/our-services/Work-and-Money/Other-Support/Calfresh-employment

## Cal-Learn

កម្មវិធី Cal-Learn បម្រើសេវាកម្មជូនក្មេងជំទង់ដែលមានផ្ទៃពោះ និងចិញ្ចឹមថែទាំកូន ដែលកំពុងទទួលជំនួយសាច់ប្រាក់តាមរយៈកម្មវិធី CalWORKs។ កម្មវិធីនេះបង្កើតឡើង ដើម្បីជួយក្មេងជំទង់ដែលចិញ្ចឹមកូន ឲ្យទទួលបានសញ្ញាបត្រថ្នាក់វិទ្យាល័យ ឬ GED និងបោះជំហានដំបូងឆ្ពោះទៅសម្រេចគោលដៅអនាគតរបស់ពួកគេ។

សេវាកម្ម រួមមាន ការគ្រប់គ្រងសំណុំរឿង ការថែទាំកុមារ និងការដឹកជញ្ជូនទៅសាលារៀន ប្រភពធនធានអប់រំ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ចំពោះលទ្ធផលសិក្សាល្អប្រសើរ និងការបញ្ចប់ការសិក្សា។

<u>លក្ខណសម្បត្តិ៖</u>

- ក្មេងជំទង់មានផ្ទៃពោះ ឬចិញ្ចឹមកូន អាយុក្រោម 19 ឆ្នាំ ដែលកំពុងទទួលអត្ថប្រយោជន៍ CalWORKs និងគ្មានសញ្ញាបត្រថ្នាក់វិទ្យាល័យ ឬ GED <u>ឬក៏</u>
- អ្នកទទួល CalWORKs ដែលមានក្មេងជំទង់មានផ្ទៃពោះ ឬចិញ្ចឹមកូន ក្នុងសំណុំរឿង ដូចសេចក្តីរៀបរាប់ខាងលើ។.

ត្រូវតែដាក់ពាក្យស្នើសុំ ឬក៏បច្ចុប្បន្នទទួល CalWORKs ដើម្បីចូលរួមក្នុងកម្មវិធី Cal-Learn។

**របៀបស្នើសុំ៖**

ត្រូវតែដាក់ពាក្យស្នើសុំ ឬក៏បច្ចុប្បន្នទទួល CalWORKs ដើម្បីចូលរួមក្នុងកម្មវិធី Cal- Learn។

**ដើម្បីស្នើសុំ CalWORKS៖**

- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ SSA
- **អនឡាញ៖** https://benefitscal.com/
  **តាមទូរស័ព្ទ**លេខ (510)272-3663
- **ប្រៃសណីយ** P.O. Box 12941 Oakland, CA 94604

- **ប្រអប់ទម្លាក់ឯកសារ** ប្រអប់ទម្លាក់ឯកសារស្នើសុំ ស្ថិតនៅការិយាល័យ SSA នីមួយៗ
- **ទូរសារ** 510-670-5095

**ដើម្បីសាកសួរអំពីកម្មវិធី Cal-Learn**

- ទាក់ទងទីប្រឹក្សាការងារជាកំណត់របស់អ្នក។

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖**:
http://www.alamedacountysocialservices.org/our-services/Work-and-Money/Other-Support/CalLearn

## Employment and Education Program (SASYEP)

យុវជនចូលរួម អាចរកបានប្រាក់ចំនួន $10 ក្នុងមួយម៉ោងពីការងាររដូវក្តៅរយៈពេល 20 ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់បទពិសោធន៍ការងាររយៈពេលអតិបរមាចំនួន 150 ម៉ោង។ ម្យ៉ាងទៀត អ្នកចូលរួមអាចរកបានប្រាក់រង្វាន់ហិរញ្ញវត្ថុសម្រាប់ការបំពេញសេចក្តីត្រូវការអប់រំរបស់ខ្លួន។ សេវាកម្មផ្សេងៗត្រូវបានផ្តល់ជូនដោយ Alameda County Workforce Development Board។

**របៀបសាកសួរ៖**

ទាក់ទងអ្នកផ្តល់សេវាកម្មយុវជន៖
https://www.acwdb.org/youth.page

## Employment Development Department

Employment Development Department (EDD) នៃរដ្ឋ California ផ្តល់សេវាកម្មជាច្រើន ដែលទាក់ទងនឹងការងារ រួមមាន៖

- សិក្ខាសាលាស្តីពីការស្វែងរកការងារ និងប្រវត្តិរូប
- ពិព៌ណការងារ ការឧទ្ទេសនាម និងការបណ្តុះបណ្តាល
- ការធានារ៉ាប់រងភាពគ្មានការងារ ជំនួយពិការភាពរបស់រដ្ឋ និងជំនួយសម្រាកដោយសារធុរៈគ្រួសារដែលមានប្រាក់ឈ្នួលសម្រាប់កម្មករដែលមានលក្ខណសម្បត្តិ

**សម្រាប់ព័ត៌មានបន្ថែម៖**

**វេបសាយ៖**: edd.ca.gov

## អ្នកចូលរួម Individualized Career Services for Limited English Proficiency (LEP)

ដៃគូសហគមន៍របស់ ACSSA ផ្តល់នូវសេវាកម្មការងារ និងការបណ្តុះបណ្តាលភាសាអង់គ្លេសជាភាសាវិជ្ជាជីវៈទីពីរ (ES/ESL) ជាពិសេសដល់អ្នកចូលរួមចេះអង់គ្លេសតិចតួច និងមិនចេះសោះ (LEP)។ គោលដៅ គឺដើម្បីទទួលបានការងារ និងឯករាជភាព។

- បុគ្គលដែលចង់ស្នើសុំជំនួយសាច់ប្រាក់ និង CalFresh ឬចុះឈ្មោះក្នុង LEP ត្រូវតែដាក់ពាក្យសុំ៖

- **ដោយផ្ទាល់**នៅទីតាំងការិយាល័យ SSA
- **អនឡាញ៖** https://benefitscal.com/
  **តាមទូរស័ព្ទ**លេខ (510)272-3663
- **ប្រៃសណីយ** P.O. Box 12941 Oakland, CA 94604

**វេបសាយ៖**
https://www.alamedacountysocialservices.org/our-services/Immigrants-and-Refugees/RCA
ឬអនឡាញនៅ http://https://benefitscal.com/

# សេវាកម្មជនអន្តោប្រវេសន៍ និងជនភៀសខ្លួន

## Services to Older Refugees (SOR)

ផ្តល់ឱកាសដល់ជនភៀសខ្លួនវ័យចាស់ ដើម្បីសិក្សាអំពីប្រព័ន្ធអប់រំ ច្បាប់ សុខភាព និងសុខភាពផ្លូវចិត្តរបស់អាមេរិក។ អ្នកចូលរួមក៏ទទួលបានសេវាកម្មផ្សេងៗផងដែរ ក្នុងនោះ រួមមានការបង្ហាត់បង្រៀនភាសា និងសិទ្ធិ និងកាតព្វកិច្ចពលរដ្ឋ និងទទួលបានឱកាសចូលរួមក្នុងសកម្មភាពលំហែកម្សាន្ត និងក្នុងព្រឹត្តការណ៍សហគមន៍ផ្សេងៗ។

លក្ខណសម្បត្តិ៖

- ជនភៀសខ្លួនអាយុ 60 ឆ្នាំ និងច្រើនជាងនេះ និង
- ពលរដ្ឋនៃខោនធី Alameda County និង
- មានលក្ខណសម្បត្តិទទួលបានអត្ថប្រយោជន៍ និងសេវាកម្មរបស់ Office of Refugee Resettlement និងបានរស់នៅក្នុងសហរដ្ឋអាមេរិក សម្រាប់រយៈពេលរហូតដល់ 60 ខែ (សេវាកម្មបញ្ជូន សេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់ និងសេវាកម្មរៀបចំស្នើសុំសញ្ជាតិ និងចូលសញ្ជាតិ សម្រាប់ជនភៀសខ្លួនទាំងនេះមានជូនក្រោយរយៈពេលប្រាំឆ្នាំ)។

**សម្រាប់ព័ត៌មានបន្ថែម៖**

- **ដោយផ្ទាល់៖** 1811 11th Avenue, Oakland, CA 94606
- **តាមទូរស័ព្ទ៖** (510) 830-6863
- **តាមអ៊ីម៉ែល៖** zarni@reftrans.org
- **វេបសាយ៖**https://reftrans.org/

## Afghan Services to Older Refugees (ASOR)

សេវាកម្ម Afghan-specific Refugee Support Services (RSS) បង្កើតឡើង ដើម្បីពង្រឹងលទ្ធភាពទទួលបានសេវាកម្ម ដែលឆ្លើយតបនឹងកត្តាវប្បធម៌ ដែលលើកកម្ពស់សុខមាលភាព

ឯករាជភាព និងការចូលរួមក្នុងសហគមន៍សម្រាប់ជនភៀសខ្លួនអាហ្វហ្គានីស្ថានវ័យចាស់។

លក្ខណសម្បត្តិ៖ ជនជាតិអាហ្វហ្គានីស្ថានអាយុ 60 ឆ្នាំ និងច្រើនជាងនេះ ដែលបានតាំងទីលំនៅជាថ្មីនៅក្នុងខោនធី Alameda។

**សម្រាប់ព័ត៌មានបន្ថែម៖**

- **ដោយផ្ទាល់៖** 1811 11th Avenue, Oakland, CA 94606
- **តាមទូរស័ព្ទ៖** (510) 830-6863
- **តាមអ៊ីម៉ែល៖** zarni@reftrans.org
- **វេបសាយ៖**https://reftrans.org/

## Refugee Social Integration (SI) Services

សេវាកម្មនេះ ត្រូវបានបង្កើតឡើង សម្រាប់មនុស្សពេញវ័យ ដែលកំពុងជួបប្រទះការលំបាកផ្នែកចិត្តសាស្ត្រ បញ្ហា សង្គម ឬរូបកាយ ក្នុងការសម្របខ្លួន។ សកម្មភាពផ្សេងៗមានគោលដៅជួយជនភៀសខ្លួនឲ្យយល់ដឹងពីរបៀបប្រើប្រាស់ និងអភិវឌ្ឍជំនាញរស់នៅប្រចាំថ្ងៃ និងជំនាញដោះស្រាយបញ្ហា។

លក្ខណសម្បត្តិ៖

- ពលរដ្ឋនៃខោនធី Alameda និង
- ជនភៀសខ្លួន ជនសុំសិទ្ធិជ្រកកោន ជនជាតិគុយបា និងហៃទី ដែលចូលទឹកដីអាមេរិក អ្នកកាន់ SIV ជនរងគ្រោះនៃអំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និង
- មានអាយុ 18 ទៅ 59 ឆ្នាំ និង
- មិនបានចុះឈ្មោះក្នុងកម្មវិធីជួយជនភៀសខ្លួន (Refugee Support Program) ផ្សេងទៀត – កម្មវិធីសេវាកម្មការងារ/បង្រៀនភាសាអង់គ្លេសជាភាសាវិជ្ជាជីវៈទីពីរ និងកម្មវិធីសម្របខ្លួនក្នុងសង្គម (Social Adjustment) (ES/VESL/SA)។

**សម្រាប់ព័ត៌មានបន្ថែម៖**

- **ដោយផ្ទាល់៖** 1811 11th Avenue, Oakland, CA 94606
- **តាមទូរស័ព្ទ៖** (510) 830-6863
- **តាមអ៊ីម៉ែល៖** zarni@reftrans.org
- **វេបសាយ៖**https://reftrans.org/

## Alameda County Immigration Legal and Education Partnership (ACILEP)

ផ្តល់ជំនួយទៅឲ្យជនអន្តោប្រវេសន៍ ដែលកំពុងជួបហានិភ័យនៃការឃុំខ្លួន និងនិរទេសចេញពីទឹកដីអាមេរិក ក្នុងអំឡុងពេលមានវិបត្តិអន្តោប្រវេសន៍នាបច្ចុប្បន្ននេះ តាមខ្សែទូរស័ព្ទបន្ទាន់ សម្រាប់ផ្ទៀងផ្ទាត់សកម្មភាពរបស់ U.S. Immigration and Customs Enforcement (ICE) នៅនឹងកន្លែង សម្រាប់សេវាកម្មផ្លូវច្បាប់បង្ការ និងក្នុងគ្រាអាសន្ន សម្រាប់ការអប់រំ និងការផ្សព្វផ្សាយ Know Your Rights (ការយល់ដឹងពីសិទ្ធិរបស់អ្នក) និងសម្រាប់ការចូលរួមស្ម័គ្រចិត្ត។

សមាជិកសហគមន៍នឹងប្រើសេវាកម្ម ACILEP តាមរយៈខ្សែទូរស័ព្ទបន្ទាន់ ដែលដំណើរការពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 6 AM ដល់ 6 PM តាមអ៊ីម៉ែល ការបញ្ជូនតាមវេបសាយ នៅ www.ACILEP.org និងការបញ្ជូនពីទីភ្នាក់ងារដៃគូ។

លក្ខណសម្បត្តិ៖
ជនអន្តោប្រវេសន៍ ដែលកំពុងស្នាក់នៅក្នុងខោនធី Alameda ដោយអាទិភាពត្រូវផ្តល់ជូនបុគ្គលមានចំណូលទាប និងអ្នកទាំងឡាយដែលមានហានិភ័យខ្ពស់បំផុតប្រឈមនឹងការឃុំខ្លួន ឬនិរទេសចេញពីទឹកដីអាមេរិក។

**ព័ត៌មានបន្ថែម៖**

- **ទូរស័ព្ទទៅខ្សែទូរស័ព្ទបន្ទាន់ ACILEP៖** (510) 241-401
- វេបសាយ៖https://www.acilep.org/

## Alameda County Removal Defense Collaborative

ផ្តល់សេវាកម្មតំណាងផ្លូវច្បាប់ សេវាកម្មអប់រំ និងសេវាកម្មគាំពារផ្សេងៗ ទៅឲ្យជនអន្តោប្រវេសន៍ និងជួយសម្របសម្រួលជាមួយនឹងបណ្តាញ Alameda County Immigration Legal and Education Partnership (ACILEP) និងអង្គការសហគមន៍ ដើម្បីធានាថា គ្រួសារទទួលបាននូវជំនួយ ជាមួយសេវាកម្មគ្រប់ជ្រុងក្នុងអំឡុងដំណើរការនីតិវិធីផ្លូវច្បាប់ទាំងមូល។

លក្ខណសម្បត្តិ៖
ជនអន្តោប្រវេសន៍ ដែលកំពុងស្នាក់នៅក្នុងខោនធី Alameda ដែលកំពុងតែប្រឈមនឹងការឃុំខ្លួន និងនិរទេសចេញពីទឹកដីអាមេរិក នៅក្នុងនិតិវិធីនិរទេសរបស់ពួកគេ។

**ព័ត៌មានបន្ថែម៖**

- **អ៊ីម៉ែល៖** info@ccijustice.org
- **វេបសាយ៖** https://www.ccijustice.org/

# សេវាកម្មមនុស្សពេញវ័យ និងចាស់ជរា

## Adult Protective Services (APS)

Adult Protective Services (APS) ឆ្លើយតបនឹងការរាយការណ៍អំពីការបំពាន (រូបកាយ ឬហិរញ្ញវត្ថុ) ឬការមិនថែទាំ (រាប់ទាំងការមិនថែទាំខ្លួនឯង) លើពលរដ្ឋខោនធី Alameda អាយុ 60 ឆ្នាំ និងលើសនេះ និងមនុស្សពេញវ័យក្នុងបន្ទុកអាយុ 18-59 ឆ្នាំ ដែលមិនអាចការពារប្រយោជន៍ខ្លួន ឬថែទាំខ្លួន ដោយសារពិការភាពរូបកាយ ឬផ្លូវចិត្ត។

សេវាកម្ម APS ត្រូវបានផ្តល់ជូនដោយមិនគិតពីចំណូលឡើយ ហើយការទទួលយកសេវាកម្ម គឺជាការស្ម័គ្រចិត្ត។

**ដើម្បីរាយការណ៍ពីការបំពាន៖**

- **ទូរស័ព្ទ៖** 1-866-CALL-APS ឬហៅទៅលេខ 1-866-CALL-APS
- **អនឡាញ៖** https://reporttoaps.org/

## Area Agency on Aging

AAA ចាប់ដៃគូជាមួយអង្គការមូលដ្ឋាន និងជួយមនុស្សចាស់ និងអ្នកថែទាំដោយផ្ទាល់ ដើម្បីលើកកម្ពស់ការចូលរួមក្នុងសង្គម សុខភាព និងសុខមាលភាព។ កម្មវិធី និងសេវាកម្ម មានគោលដៅ ដើម្បីបង្ការភាពឯកោ ការដាក់ចូលក្នុងគ្រឹះស្ថានមុនកាលកំណត់ ការបំពាន និងលទ្ធភាពសុខភាពអវិជ្ជមានសម្រាប់ចាស់ជរា (អាយុ 60 ឆ្នាំ ឬលើសនេះ)។

សេវាកម្មរួមមាន ដូចជា៖ ការថែទាំមនុស្សពេញវ័យពេលថ្ងៃ ការគ្រប់គ្រងសំណុំរឿង សេវាកម្មសហគមន៍ ការអប់រំបង្ការការបំពានលើចាស់ជរា ការឧបត្ថម្ភអ្នកថែទាំក្នុងគ្រួសារ ការលើកកម្ពស់សុខភាព សេវាកម្មធានារ៉ាប់រងសុខភាព ប្រឹក្សា និងនិយាយគាំទ្រ (HICAP) ព័ត៌មាន & ជំនួយ សេវាកម្មផ្លូវច្បាប់ កម្មវិធីអាហារូបត្ថម្ភ កម្មវិធី Ombudsman ការងារចាស់ជរា និងការបង្ការរបួសលើចាស់ជរា។

### សម្រាប់ព័ត៌មានបន្ថែម៖

- ទូរស័ព្ទទៅផ្នែកព័ត៌មាន និងជំនួយចាស់ជរា (Senior Information and Assistance) លេខ 1-800-510-2020 ឬ 510-577-353
- **ចូលទៅ៖** seniorinfo.acgov.org
- **ទំព័រវេបសាយ៖** https://www.alamedacountysocialservices.org/our-services/Seniors-and-Disabled/Area-Agency-on-Aging/Senior-Information-and-Assistance/Senior-Information-and-Assistance#resourceguides

## សេវាកម្មគាំពារនៅផ្ទះ (In-Home Supportive Services)

កម្មវិធី IHSS ផ្តល់ជំនួយទៅឲ្យចាស់ជរា ជនពិការភ្នែក និងជនមានពិការភាព ដែលមានចំណូលទាប ដើម្បីឲ្យពួកគេអាចបន្តរស់នៅដោយសុវត្ថិភាពនៅក្នុងផ្ទះរបស់ខ្លួន។ កម្មវិធី IHSS ផ្តល់សេវាកម្មផ្អែកតាមសមត្ថភាពរបស់អតិថិជនក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ។ សេវាកម្មអាចរួមមាន ការបញ្ចុកអាហារ ការងូតទឹក ការស្លៀកពាក់ ការសម្អាតផ្ទះ ការបោកគក់ ការដើរផ្សារ និងការរៀបចំចម្អិនអាហារ និងការសម្អាត ការថែទាំផ្លូវដង្ហើម ពោះវៀន និងប្លោកនោម ឲ ការអមដំណើរក្នុងការណាត់ជួបវេជ្ជសាស្ត្រ សេវាកម្មជំនួយផ្នែកវេជ្ជសាស្ត្រ និងការត្រួតពិនិត្យការរពារ។

<u>លក្ខណសម្បត្តិ៖</u>

ដើម្បីមានលក្ខណសម្បត្តិសម្រាប់កម្មវិធី IHSS ត្រូវតែបំពេញនូវលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានអាយុ 65 ឆ្នាំឡើង ពិការ និង/ឬពិការភ្នែក និង
- ទទួលបាន full-scope Medi-Cal និង
- រស់នៅក្នុងខោនធី Alameda និង
- មិនអាចរស់នៅក្នុងផ្ទះដោយសុវត្ថិភាព បើគ្មានជំនួយ

របៀបស្នើសុំ៖

- **ទូរស័ព្ទ៖** 510-577-1800
- **ដោយផ្ទាល់៖** Adult & Aging Services Lobby
(ថ្ងៃចន្ទ-ថ្ងៃសុក្រFriday, 8:30 am - 5:00 pm)
6955 Foothill Boulevard 1st floor - Suite 143
Oakland, CA 94605
- **ប្រៃសណីយ៍៖** 6955 foothill Blvd., Suite 300, Oakland CA 94605
- **ទូរសារ៖** 510-577-1803

## សេវាកម្មកុមារ និងគ្រួសារ

## ផ្នែកស៊ើបអង្កេតការបំពាន និងការធ្វេសប្រហែស

**ខ្សែទូរស័ព្ទបន្ទាន់ស្តីពីការបំពានលើកុមារ/ការឆ្លើយតបក្នុងគ្រាអាសន្ន សម្រាប់សេវាកម្ម Child Protective Services របស់ខោនធី៖**

**ខ្សែទូរស័ព្ទបន្ទាន់ 24 ម៉ោង៖ 510-259-1800**

ខ្សែទូរស័ព្ទបន្ទាន់ឆ្លើយតបនឹងអង្គភាពអនុវត្តច្បាប់ មន្ទីរពេទ្យ បុគ្គលមានកាតព្វកិច្ចត្រូវរាយការណ៍ និងសាធារណជន ដែលហៅទូរស័ព្ទ ដើម្បីរាយការណ៍ពីករណីបំពានលើកុមារ ឬដើម្បីទទួលបានព័ត៌មាន។ ខ្សែទូរស័ព្ទបន្ទាន់ក៏ផ្តល់ការប្រឹក្សាយោបល់អំពីលទ្ធភាពបញ្ជូនបន្ត និងផ្តល់ព័ត៌មានពីសេវាកម្មសហគមន៍ផងដែរ។

អំឡុងម៉ោងធ្វើការ (7:30 am - 5:30 pm ថ្ងៃធ្វើការ) ផ្នែកពិនិត្យឆ្លើយតបសង្គ្រោះបន្ទាន់ គឺជាផ្នែកទទួលនូវការបញ្ជូនបន្ត និងការរាយការណ៍តាមខ្សែទូរស័ព្ទបន្ទាន់អំពីកុមារ ដែលសង្ស័យថា ស្ថិតក្នុងគ្រោះថ្នាក់ដោយសារការបំពាន ការធ្វេសប្រហែស ឬការកេងប្រវ័ញ្ច។

ក្រោយម៉ោងធ្វើការ (7:00 pm - 7:00 am) និងនៅថ្ងៃចុងសប្តាហ៍/ថ្ងៃឈប់សម្រាក ផ្នែក Eden Information and Referral (Eden I&R) ជាអ្នកទទួលទូរស័ព្ទ ហើយត្រូវបញ្ជូនបន្តទៅឲ្យបុគ្គលិកប្រចាំការក្រោយម៉ោងធ្វើការ។

## Child Abuse Prevention Services and Resources

កិច្ចប្រឹងប្រែងបង្ការ ពឹងផ្អែកលើចំណុចខ្លាំងរបស់គ្រួសារ។ តាមរយៈសកម្មភាពបង្ការ ដូចជា ការអប់រំមាតាបិតា ការចុះពិនិត្យដល់ផ្ទះ និងក្រុមពិភាក្សាគាំទ្ររបស់មាតាបិតា គ្រួសារជាច្រើនអាចស្វែងរកជំនួយ ដែលពួកគេត្រូវការ ដើម្បីរស់នៅជា មួយគ្នា និងថែទាំកូនៗរបស់ពួកគេ នៅក្នុងលំនៅឋាន និងសហគមន៍របស់ពួកគេ។ កិច្ចប្រឹងប្រែងបង្ការជួយឪពុកម្តាយឲ្យអភិវឌ្ឍជំនាញចិញ្ចឹមថែទាំកូន ឲ្យយល់ដឹង និងបំពេញសេចក្តីត្រូវការផ្លូវអារម្មណ៍ ផ្លូវកាយ និងការលូតលាស់របស់កូនៗរបស់ពួកគេ។

កម្មវិធីបង្ការក៏អាចជួយឪពុកម្តាយកំណត់ឃើញនូវសេចក្តីត្រូវការផ្សេងទៀត ដែលពួកគេអាចមាន និងជួយឲ្យពួកគេទទួលបានជំនួយបន្ថែមនោះ។

ក្រុមប្រឹក្សាបង្ការការបំពានលើកុមារ (Child Abuse Prevention Council) គឺជាស្ថាប័នមួយ បង្កើតឡើងនៅឆ្នាំ 1978 ដើម្បីជម្រុញកិច្ចប្រឹងប្រែងសហការគ្នាក្នុងកិច្ចការពារកុមារ និងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍ និងការសម្របសម្រួលសេវាកម្មកុមារនៅទូទាំងខោនធី។ នេះរួមមាន ការកំណត់វក៏ករណីបំពាន និងធ្វេសប្រហែសចំពោះកុមារ ការរាយការណ៍ ការបង្ការ កិច្ចអន្តរាគមន៍ ការព្យាបាល និងការយល់ដឹងរបស់សាធារណជន។

សមាជិកក្នុងក្រុមប្រឹក្សារួមមានបុគ្គល ទីភ្នាក់ងារ និងស្ថាប័ន ដែលព្រួយបារម្ភអំពីបញ្ហាបំពាន និងធ្វេសប្រហែសចំពោះកុមារ។ ក្រុមប្រឹក្សាមានសកម្មភាពយ៉ាងសកម្មជាច្រើនដែលជួយបង្ការការបំពានលើកុមារ។

ដើម្បីស្វែងយល់បន្ថែម សូមចូលទៅវេបសាយរបស់ Alameda County Child Abuse Prevention Counci (https://www.alamedacountycapc.com/)

## ការបង្រួបបង្រួម & ការទ្រទ្រង់គ្រួសារ

**ការបង្រួបបង្រួមគ្រួសារ (Family Reunification (FR))** មានគោលដៅ ដើម្បីបង្រួបបង្រួមកុមារជាមួយឪពុក/ម្តាយ នៅក្នុងផ្ទះដែលមានសុវត្ថិភាព ស្ថេរភាព និងការគាំពារ។ សំណុំរឿង FR ទាំងអស់ ពាក់ព័ន្ធនឹងកុមារ ដែលត្រូវយកចេញពីការថែទាំ និងការគ្រប់គ្រងរបស់ឪពុក/ម្តាយ។ សេវាកម្មបង្រួបបង្រួមគ្រួសារ ត្រូវបានផ្តល់ជូនសម្រាប់រយៈពេល ទៅតាមកំណត់ក្នុងច្បាប់រដ្ឋ និងរដ្ឋសហព័ន្ធ។

**ការទ្រទ្រង់គ្រួសារ (Family Maintenance (FM))** ធ្វើការជាមួយគ្រួសារ ដែលកូនត្រូវបានកំណត់ថាស្ថិតនៅក្នុងបន្ទុករបស់តុលាការដោយសារការបំពាន ឬការធ្វេសប្រហែស ប៉ុន្តែកូននោះបន្តស្នាក់នៅក្នុងផ្ទះ ដោយផ្អែកលើការវាយតម្លៃសុវត្ថិភាពដែលកំពុងបន្តធ្វើខណៈពេលកំពុងផ្តល់សេវាកម្ម។ គោលដៅ គឺដើម្បីទ្រទ្រង់ និងពង្រឹងគ្រួសារ ពេលណាអាចធ្វើទៅបាន។

**ការទ្រទ្រង់គ្រួសារក្រៅផ្លូវការ** គឺជាកិច្ចអន្តរាគមន៍ក្រៅផ្លូវតុលាការសម្រាប់គ្រួសារ ដែលចង់ចូលរួមនៅក្នុងសេវាកម្មស្ម័គ្រចិត្ត និងកម្មវិធីនៃការគ្រប់គ្រងសំណុំរឿងក្រៅផ្លូវការ។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មទ្រទ្រង់ ឬថែរក្សាគ្រួសារ សូមចូលទៅ៖
https://www.alamedacountysocialservices.org/our-services/Youth/other-support/family-maintenance

## សេវាកម្មអាណាព្យាបាល

បុគ្គលជាសាច់ញាតិ និងមិនមែនជាសាច់ញាតិ អាចក្លាយជាអាណាព្យាបាលស្របច្បាប់លើកូនចិញ្ចឹមបាន។

អង្គភាពអាណាព្យាបាលភាពផ្លូវច្បាប់របស់ Social Services Agency ធ្វើការជាមួយនឹងអាណាព្យាបាល ដែលកំពុងស្នាក់នៅក្នុងខោនធីAlameda ដែលមិនមែនជាសាច់ញាតិ ដែលកំពុងទទួលជំនួយឧបត្ថម្ភធនលើការថែទាំចិញ្ចឹមកូន។

បុគ្គលិក Child Welfare បន្តទាក់ទងជាមួយអាណាព្យាបាល និងយុវជន ដោយជួបពួកគេយ៉ាងតិចពីរដងក្នុងមួយឆ្នាំ (រៀងរាល់ 6 ខែ) ដោយផ្តល់សេវាកម្មគ្រប់គ្រងសំណុំរឿង ដែលសង្កត់ធ្ងន់លើការបញ្ជូនបន្ត និងកិច្ចអន្តរាគមន៍។

សម្រាប់ព័ត៌មានបន្ថែម៖
https://www.alamedacountysocialservices.org/our-services/Youth/resource-families/tabs/legal-guardianship-adoption

## សេវាកម្មថែទាំចិញ្ចឹម

**សេវាកម្មស្វែងរកទីកន្លែង** ផ្តល់សេវាកម្មដែលឆ្លើយតប និងគ្រប់ជ្រុងជ្រោយ ទៅឲ្យកុមារ ដែលត្រូវការកន្លែងផ្សេងក្រៅពីផ្ទះ។ ការដាក់ឲ្យនៅផ្ទះរបស់សាច់ញាតិដែលចង់ទទួលកុមារ គឺជាជម្រើសទីមួយ សម្រាប់កុមារគ្រប់រូប។

**លក្ខណសម្បត្តិសម្រាប់ការថែទាំចិញ្ចឹម** កំណត់លក្ខណសម្បត្តិលើកដំបូង និងបន្តបន្ទាប់របស់កុមារក្នុងការថែទាំក្រៅផ្ទះសម្រាប់ជំនួយពីកម្មវិធី Medi-Cal និងកម្មវិធីជំនួយហិរញ្ញវត្ថុផ្សេងទៀត ដូចជា កម្មវិធីជំនួយគ្រួសារមានកូនក្នុងបន្ទុក - ការថែទាំចិញ្ចឹម (Aid to Families with Dependent Children – Foster Care (AFDC-FC))។

**ខ្សែទូរស័ព្ទព័ត៌មានស្តីពីការថែទាំចិញ្ចឹម៖**
510-268-2500

អ្នកថែទាំ និងអ្នកផ្តល់សេវាកម្មបច្ចុប្បន្នអាចហៅទូរស័ព្ទ ដើម្បីសួរសំណួរពាក់ព័ន្ធនឹងលក្ខណសម្បត្តិទាក់ទងនឹងកូនចិញ្ចឹម។

## ការសុំកូន

Social Services Agency នៃខោនធី Alameda ទទួលបានអាជ្ញាប័ណ្ណទីភ្នាក់ងារសុំកូនសាធារណៈដែលចេញដោយក្រសួងសេវាសង្គមកិច្ចនៃរដ្ឋ California។ កម្មវិធីសុំកូនផ្តល់សេវាកម្មទាក់ទងនឹងការសុំកូនក្នុងបន្ទុករបស់តុលាការ ក្នុងប្រព័ន្ធសង្គមកិច្ចកុមារ ដែលនេះគឺជាដំណើរការ ហៅថា ការសុំកូនតាមរយៈទីភ្នាក់ងារ។

កម្មវិធីសុំកូន ក៏ផ្តល់សេវាកម្មសុំកូនដោយឯករាជ្យ និងដោយឪពុក/ម្តាយចុង សម្រាប់កូនដែលមិនស្ថិតក្នុងបន្ទុកផងដែរ។

សម្រាប់ព័ត៌មានបន្ថែម៖
https://www.alamedacountysocialservices.org/our-services/Youth/resource-families/tabs/legal-guardianship-adoption

- **ការសុំកូន ព័ត៌មានទូទៅ៖** 510-268-2422
- **ការសុំកូន ឪពុក/ម្តាយចិញ្ចឹម ព័ត៌មានអាជ្ញាប័ណ្ណចិញ្ចឹមកូន៖** 510-259-3575
- **ការសុំកូនដោយបុគ្គលឯករាជ្យ៖** 510-268-2428
- **ការសុំកូនដោយឪពុក/ម្តាយចុង៖** 510-268-4276

## សេវាគាំពារសាច់ញាតិ (Kinship Support Services (KSSP))

សេវាកម្មគាំពារគ្រួសារក្នុងសហគមន៍សម្រាប់អ្នកថែទាំជាសាច់ញាតិ និងកុមារ នៅក្នុងផ្ទះរបស់ពួកគេ រួមមាន៖

**Family Support Services of the Bay Area**
ទូរស័ព្ទ៖ 510-834-2443
401 Grand Ave #500 Oakland, CA 94610

**Lincoln Child Center**
ទូរស័ព្ទ៖ 510-583-8026
1149 A Street Hayward, CA 94541

## សេវាកម្មរៀបចំបង់ពន្ធ ឥតគិតថ្លៃ

## កម្មវិធីជំនួយស្ម័គ្រចិត្តរៀបចំបង់ពន្ធចំណូល (Volunteer Income TAX Assistance (VITA) Program)

សេវាកម្មរៀបចំបង់ពន្ធឥតគិតថ្លៃ គឺមានជូនអតិថិជនរបស់ Social Service Agency និងបុគ្គល និងគ្រួសារចំណូលទាប ក្នុងខោនធី Alameda ទាំងមូល។ អ្នករៀបចំបង់ពន្ធស្ម័គ្រចិត្ត ដែលមានលិខិតបញ្ជាក់ពី IRS របស់យើង ជួយធានាថា អ្នកជាប់ពន្ធចំណូលទាប ទទួលបានរាល់ក្រេឌីត និងការកាត់ប្រាក់ពន្ធទាំងអស់ ដែលពួកគេទទួលបាន។

កម្មវិធី VITA ដំណើរការជាប្រចាំឆ្នាំ ពីចុងខែមករា ដល់ពាក់កណ្តាលខែមេសា។

**របៀបស្នើសុំ៖**
**ត្រូវណាត់ជួប**នៅទីតាំងរៀបចំបង់ពន្ធរបស់ ACSSA។ ចូលអនឡាញ ដើម្បីកំណត់កាលវិភាគណាត់ជួប៖

https://public.alamedasocialservices.org/EITCScheduler/Account/Login?returnUrl=%2FEITCScheduler

**សម្រាប់ព័ត៌មានបន្ថែម៖**

- **ទូរស័ព្ទ៖** 510-271-9141
- **អ៊ីម៉ែល៖** vita.eitc@acgov.org
- **វេបសាយ៖**

https://www.alamedacountysocialservices.org/our-services/Work-and-Money/Other-Support/tax-services

## ធនធានសហគមន៍

NEWCOMERS WELCOME

**Newcomers Welcome**
https://newcomerswelcome.acgov.org

EAST BAY REFUGEE & IMMIGRANT FORUM

**East Bay Refugee and Immigrant Forum**
510-473-2881
https://www.ebrif.org/